# ទុក្ខរបស់ប្រជាពលរដ្ឋ ?

នៅក្នុងរជ្ជកាល ព្រះបាទជ័យវរ្ម័នទី៧ មានសិលាចារឹកចារថា « ទុក្ខរបស់ប្រជានុរាស្ត្រ ជាទុក្ខរបស់ព្រះមហាក្សត្រ »។ បើអ្នកបានឮពាក្យស្លោកនេះ ដោយមិនបានយកវាមកពិចារណា វាច្បាស់ជាយល់ឃើញថា ព្រះមហាក្សត្រ ព្រះអង្គមានព្រះរាជហឫទ័យករុណាពិត ដល់ប្រជានុរាស្ត្រ។ ជាការពិត នៅក្នុងបរិបទនៃអំណាចផ្តាច់ការ អ្វីមួយ ដែលជាសេចក្តីមេត្តារបស់អ្នកដឹកនាំ វាទុកជាគុណធម៌របស់នរៈនោះ ព្រោះប្រជានុរាស្ត្រ ជា រាស្ត្រ (sujet) បើខ្លួនមានទុក្ខ តែបើទុក្ខនោះ វាមិនមែនជាការយល់ឃើញផងដែររបស់ស្តេច ថាជាទុក្ខផ្ទាល់របស់ព្រះអង្គ វាអាចមិនទុកជាទុក្ខ។ ដូចយ៉ាង ព្រះមហាក្សត្រ កេណ្ឌរាស្ត្រធ្វើទាហាន ដើម្បីធ្វើសង្គ្រាម បំរើមហិច្ឆិតាផ្ទាល់របស់ព្រះអង្គ នាំអោយប្រជានុរាស្ត្រ មានទុក្ខ តែទុក្ខនោះ វាផ្ទុយពីផលប្រយោជន៏របស់ព្រះអង្គ។ តែនៅក្នុងលទ្ធិប្រជាធិបតេយ្យ ទុក្ខរបស់ប្រជាពលរដ្ឋ វាអាចទុកជាកំហុសរបស់អ្នកដឹកនាំ ហើយពលរដ្ឋអាចមានសិទ្ធិរិះគន់ ឬ ប្តឹងចោទប្រកាន់ទៀតផង។ នៅក្នុងករណីបែបនេះ គេទុកអ្នកដឹកនាំ ជា « ជនបំរើ » ប្រជាពលរដ្ឋ ហើយ ពលរដ្ឋជា « ជនប្រើ » អំណាចរបស់ប្រជាពលរដ្ឋ ដែលមានចែងនៅក្នុងច្បាប់។ ដូច្នេះ ទុក្ខរបស់ប្រជាពលរដ្ឋ វាមិនមែនជាទុក្ខរបស់អ្នកដឹកនាំនោះឡើយ ផ្ទុយទៅវិញ វាជាការ

## ទុក្ខរបស់ប្រជាពលរដ្ឋ ?

ទទួលខុសត្រូវរបស់នរៈនោះ ជាកាតព្វកិច្ចលំអិត នៅចំពោះមុខប្រជាពលរដ្ឋ។ ព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គ ប្រហែលជាមានករុណាចំពោះទុក្ខរបស់រាស្ត្រពិតមែន តែជាករុណា ជាជម្រើសផ្ទាល់របស់ព្រះអង្គ មិនមែនជា កាតព្វកិច្ចក្នុងច្បាប់ ជាដឹកនាំនោះឡើយ។ ដូចសព្វថ្ងៃ របបក្រុងភ្នំពេញ ដែលជារបបផ្តាច់ការ រមែងធ្វើទុក្ខបុកម្នេញជនខ្មែរទាំងឡាយ ដើម្បីការពារអំណាចរបស់ខ្លួន ហើយមិនដែល យល់ឃើញថាទុក្ខនោះជាទុក្ខរបស់ប្រជាពលរដ្ឋនោះឡើយ។ ផ្ទុយទៅវិញ បើខ្លួនបញ្ចប់ការបៀតបៀនទៅលើអ្នករងគ្រោះ, ហ៊ុន សែន គាត់ថាកិច្ចនោះ ជាសេចក្តីមេត្តាធម៌ របស់រាជរដ្ឋាភិបាល។ ពិតណាស់ហើយ ថា យើងមិនយកបុគ្គល ហ៊ុន សែន មកប្រៀបផ្ទឹមនឹងព្រះបាទជ័យវរ្ម័នទី៧ នោះទេ តែគ្រាន់តែចង់បង្ហាញថា នៅក្នុងរបបផ្តាច់ការគ្រប់ធម្មជាតិ គេនិយមទុកប្រជាជន ជាឧបករណ៍ សំរាប់បំរើផលប្រយោជន៍ របស់គេតាមគ្រប់មធ្យោបាយ តាំងតែនៅក្នុងពាក្យសំដី ដែលនាំនរូទាំងឡាយអោយយល់ច្រឡំអំពីធាតុពិត នៃសំដី។ ជួនកាល ការភ្ញាក់ដឹងខ្លួន វាហួសពេលវេលា ព្រោះរបបផ្តាច់ការ គេពង្រាលអាវុធ សំរាប់ធ្វើការសង្កិតសង្កិន របស់គេបានសព្វគ្រប់ តាមការបោកប្រាស់នោះ។ ដូច្នេះ បើប្រជានុរាស្ត្រ ជួបប្រទះនឹងទុក្ខ គឺមានតែខ្លួនឯង ជាអ្នករកមធ្យោបាយតាមផ្លូវច្បាប់ ដោយប្រើអំណាចនៃប្រជាពលរដ្ឋ ព្រោះទុក្ខរបស់ខ្លួន វាអាចអ្នកដឹកនាំគេយល់ឃើញថាជាអំពើក្បត់ជាតិទៅវិញ៕

**ឧប សៅ សន្ធា** **តំនិត** **១៥ វិច្ឆិកា ២០១៩**